# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា
PHILADELPHIA, PENNSYLVANIA 19130

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤

ជូនចំពោះ មាតាបិតា/អាណាព្យាបាល៖

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ ក្រសួងអប់រំនៃរដ្ឋធិនស៊ីលវេនញ៉ា បានទទួលការលើកលែងពីការតម្រូវដប់ នៃច្បាប់អប់រំ សាលាបឋមសិក្សា និង វិទ្យាល័យ - Elementary and Secondary Education Act (ESEA) នៃឆ្នាំ១៩៦៥ ដូចបានកែតម្រូវ ដោយច្បាប់ មិនបន្សល់កុមារ - No Child Left Behind (NCLB) នៃឆ្នាំ២០០១។ ទោះជាដូច្នេះក៏ដោយ ច្បាប់ ESEA/NCLB នៅតែតម្រូវឲ្យជម្រាបទៅមាតាបិតា ឬ អាណាព្យាបាល ដែលមានកូនទៅរៀននៅសាលាដែលឧបត្ថម្ភដោយច្បាប់ Title I អំពីជោគជ័យនៃការសិក្សារបស់សាលា ព្រមទាំងការចាត់តាំងរបស់សាលា ក្រោមច្បាប់ ESEA ដែលអាចលើកលែង របស់រដ្ឋធិនស៊ីលវេញ៉ា។ លិខិតនេះគឺជាការផ្តល់ព័ត៌មានបន្ថែម ដែលទាក់ទងនឹងឱកាសនៃការជ្រើសរើសសម្រាប់កូនលោកអ្នក ក្រោមច្បាប់ ESEA ដែលអាចលើកលែង របស់រដ្ឋធិនស៊ីលវេញ៉ា និង ដើម្បីជួយឲ្យលោកអ្នកយល់នូវពាក្យ លើកលែង ថាមានន័យដូចម្តេច សម្រាប់លោកអ្នក និង កូនរបស់លោកអ្នក។

ចាប់ផ្តើមពីឆ្នាំសិក្សា២០១៣-១៤ ក្រសួងអប់រំនៃរដ្ឋធិនស៊ីលវេញ៉ា (PDE) ឈប់ប្រើ ការរីកចម្រើនតាមកម្រិតដែលបានកំណត់ប្រចាំឆ្នាំ (AYP) ដើម្បីសម្រេចអំពី ការចាត់តាំងនៃការកែលម្អសាលា របស់សាលាទៀតហើយ។ ផ្ទុយទៅវិញ ដោយអនុលោមតាមច្បាប់ ESEA ដែលអាចលើកលែង របស់រដ្ឋធិនស៊ីលវេញ៉ា ក្រសួងអប់រំនៃរដ្ឋធិនស៊ីលវេញ៉ាប្រើ ផែនការនៃការស្ទង់មើលប្រចាំឆ្នាំ (AMOs) បួន ដើម្បីសម្រេចការចាត់តាំងរបស់សាលា។ ផែនការនៃការស្ទង់មើលប្រចាំឆ្នាំ (AMOs) បួន គឺ៖

១. ស្ទង់មើលកម្រិតនៃការចូលរួមប្រឡង
២. កម្រិត នៃការបញ្ចប់ការសិក្សា/វត្តមានអវត្តមាន
៣. ការលប់បំបាត់គម្លាតនៃជោគជ័យក្នុងការសិក្សារបស់សិស្សានុសិស្សទាំងអស់
៤. ការលប់បំបាត់គម្លាតនៃជោគជ័យក្នុងការសិក្សា ចំពោះសិស្សានុសិស្សដែលមានប្រវត្តិរៀនខ្សោយ។

គេប្រើផែនការនៃការស្ទង់មើលប្រចាំឆ្នាំ ថ្មីនេះ ជាមូលដ្ឋានសម្រាប់ចាត់តាំងសាលាថ្មី ដែលឧបត្ថម្ភដោយច្បាប់ Title I ជំនួសការចាត់តាំងសាលាដែលត្រូវការកែលម្អ។ ការចាត់តាំងសាលាថ្មីដែលឧបត្ថម្ភដោយច្បាប់ Title I គឺ៖

- សាលាសំខាន់ជាងគេ
- សាលាដែលគេយកចិត្តទុកដាក់
- រង្វាន់ - ការរីកចម្រើនកម្រិតខ្ពស់
- រង្វាន់ - ជោគជ័យកម្រិតខ្ពស់។

សូមមើលលិខិតភ្ជាប់មកជាមួយនេះ ដើម្បីឲ្យដឹងពីលក្ខណៈវិនិច្ឆ័យសម្រាប់ការចាត់តាំងទាំងនេះ។ ក្រៅពីការចាត់តាំងទាំងបួនខាងលើនេះ ក៏មានសាលាដែលទទួលការចាត់តាំងឧបត្ថម្ភដោយច្បាប់ «Title I – គ្មានការចាត់តាំង/Title I – No Designation» ផងដែរ។

សាលារដ្ឋទាំងអស់ដែលនៅក្នុងរដ្ឋ នឹងទទួល ពិន្ទុអំពីលទ្ធផលនៃដំណើរការរបស់សាលា (School Performance Profile) ដែលយោងទៅលើ១០០ពិន្ទុ។ គេនឹងចាត់ទុកពិន្ទុនេះថាជាពិន្ទុអំពីលទ្ធផលនៃការសិក្សារបស់សាលា ហើយដោយលក្ខណៈវិនិច្ឆ័យមិនមែនជាការសម្រេចនៃ រង្វាន់ សាលាដែលសំខាន់ជាងគេ ឬ សាលាដែលគេយកចិត្តទុកដាក់ វាជាការរៀបរាប់អំពីលទ្ធផលរបស់សិស្ស តាមរយៈការឲ្យពិន្ទុ តាមរង្វាស់ជាច្រើន ដែលកំណត់ពីជោគជ័យរបស់សិស្ស។ លទ្ធផលនៃដំណើរការរបស់សាលា ក៏រួមបញ្ចូលការគាំទ្រ ដើម្បី

អនុញ្ញាតឲ្យសាលាមាន សម្ភារៈសិក្សា និង ជំនួយ ដើម្បីកែលម្អ នូវរាល់ចំណុចដែលគេបានកំណត់ដែលទាក់ទងនឹងជោគជ័យនៃការសិក្សា។

ទោះជាសិស្សានុសិស្សរបស់យើងមានការរីកចម្រើនក៏ដោយ ក៏គេបានចាត់តាំងសាលារបស់យើងជាសាលា**ដែលសំខាន់ជាងគេ។** ការចាត់តាំងនេះយោងទៅលើទិន្នន័យនៃការប្រឡងពីឆ្នាំសិក្សា ២០១២-១៣ ហើយសាលារបស់យើងនឹងរក្សាការចាត់តាំងនេះសម្រាប់រយៈពេលបីឆ្នាំ។

ជាសាលា**ដែលសំខាន់ជាងគេ** យើងខ្ញុំនឹងសហការជាមួយ មាតាបិតា/អាណាព្យាបាល សហគមន៍ និង រដ្ឋបាល របស់យើង ដើម្បីអភិវឌ្ឍផែនការបង្វែរទិសដៅរបស់សាលា ដែលនឹងអនុវត្តការធ្វើអន្តរាគមន៍ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ ក្នុងការកែលម្អលទ្ធផលនៃការសិក្សារបស់សិស្ស ក្រុមតូចៗដែលរៀនខ្សោយ របស់យើង។ **សូមទាក់ទងបុគ្គលិកសាលា សម្រាប់ការធ្វើអន្តរាគមន៍ដែលកំពុងអនុវត្តសម្រាប់ឆ្នាំសិក្សា ២០១៤-១៥។**

ដើម្បីស្វែងយល់អំពី លទ្ធផលនៃដំណើរការរបស់សាលា របស់យើង សូមមើលវិបសៃ http://paschoolperformance.org/
នៅពេលដែលចូលមើលទំព័រវិបសៃ លទ្ធផលនៃដំណើរការរបស់សាលា របស់រដ្ឋផិនស៊ីលវេញ៉ា

- ដើម្បីចាប់ផ្តើម សូមជ្រើសរើស "Role" of "Parent (In State)" នៅខាងក្រោមទំព័រ
- រកមើលសាលាទៅតាមឈ្មោះរបស់សាលា

ជាផ្នែកដ៏សំខាន់សម្រាប់ផែនការដែលនាំឲ្យមានជោគជ័យដល់សាលារបស់យើង គឺ ការចូលរួម និង ការគាំទ្រ របស់មាតាបិតាក្នុងការអភិវឌ្ឍន៍សកម្មភាព ដើម្បីបង្កើនជោគជ័យរបស់សិស្ស។ យើងខ្ញុំសង្ឃឹមថា លោកអ្នកដែលជា មាតាបិតា/អាណាព្យាបាល នឹងចូលរួមក្នុងផែនការកែលម្អសាលារបស់យើង នៅពេលដែលយើង បន្តការតាមដានជោគជ័យរបស់សិស្ស និង មានសេចក្តីសង្ឃឹមខ្ពស់។ បើសិនជាលោកអ្នកមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងផែនការកែលម្អសាលារបស់យើង ឬ ចង់ស្វែងយល់ថែមទៀតអំពី លទ្ធផលនៃដំណើរការរបស់សាលា សូមទាក់ទងទៅសាលា។

សូមអរគុណចំពោះអ្វីៗដែលលោកអ្នកបានធ្វើ ដើម្បីគាំទ្រដល់ការអប់រំរបស់កូនលោកអ្នក។

ដោយសេចក្តីស្មុំគ្រស្មោះ

នាយកសាលា